# ឯកសារសង្ខេបស្ដីពី ផែនការវិនិយោគ

# កម្មវិធី កិច្ចសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលី ដើម្បី សេវាប្រកបដោយ សមធម៌ និងនិរន្តរភាព

## (ACCESS)

## ទិន្នន័យមូលដ្ឋានរបស់កម្មវិធីកិច្ចសហប្រតិបត្តិការ កម្ពុជា-អូស្រ្តាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព

| | |
|---|---|
| **ប្រទេស៖** | ព្រះរាជាណាចក្រកម្ពុជា |
| **ឈ្មោះសកម្មភាព៖** | កម្មវិធី កិច្ចសហប្រតិបត្តិការ កម្ពុជា-អូស្រ្តាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព |
| **កម្មវិធី៖** | ទ្វេភាគី |
| **ទីតាំងសកម្មភាព៖** | ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ – នឹងមានការកំណត់ទីតាំងថ្នាក់ក្រោមជាតិ តែរំពឹងថាចំនួនមានកម្រិត |
| **ស្ថាប័នសមភាគី៖** | ក្រសួងកិច្ចការនារី<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រុមប្រឹក្សាសកម្មភាពជនពិការ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>រដ្ឋបាលថ្នាក់រាជធានី ខេត្ត<br>រដ្ឋបាលថ្នាក់ស្រុក/ខណ្ឌ និងក្រុមប្រឹក្សាឃុំ/សង្កាត់ រួមទាំងគណកម្មការស្រ្តី និងកុមារឃុំ/សង្កាត់ និងគណកម្មការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការឃុំ |
| **អ្នកម៉ៅការគ្រប់គ្រង៖** | នឹងមានការតែងតាំង – ការដេញថ្លៃបើកចំហ |
| **រយៈពេល៖** | ៥ ឆ្នាំកន្លះ (១ មករា ២០១៨ ដល់ ៣០ មិថុនា ២០២៣) |

### កាលបរិច្ឆេទសំខាន់ៗ៖

| | |
|---|---|
| បើកទទួលសំណើ | ខែកញ្ញា ដល់វិច្ឆិកា ២០១៧ |
| គៀងគរកេធនធាន | ខែធ្នូ ២០១៧ |
| ចាប់ផ្ដើមការអនុវត្ត | ទី១ ខែមករា ឆ្នាំ ២០១៨ |
| ការវាយតម្លៃលទ្ធផល | ឆ្នាំទី ៥ (ឆ្នាំ ២០២២-២០២៣) |

### ថវិការបស់សកម្មភាព៖

| | |
|---|---|
| រដ្ឋាភិបាលអូស្រ្តាលី (GoA) | ២៥ លានដុល្លារអូស្រ្តាលី |
| រាជរដ្ឋាភិបាលកម្ពុជា (RGC) | មិនទាន់ដឹង –<br>រំពឹងថានឹងមានការគាំទ្រជាសម្ភារៈ (ការិយាល័យ គ្រឹះស្ថាន) រំពឹងការកើនឡើងនូវថវិកាជាតិទទួលខុសត្រូវក្នុងការផ្តល់សេវាប្រកបដោយបរិយាប័ណ្ណ អំឡុងពេលអនុវត្តកម្មវិធី |

**សេចក្តីថ្លែងអំណរគុណ និងការបដិសេធមិនទទួលខុសត្រូវ**

ក្រុមរៀបចំគម្រោងកម្មវិធីយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតំណាងរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ។ ក្រុមយើងខ្ញុំ ក៏សូមថ្លែងអំណរគុណ រដ្ឋមន្រ្តីក្រសួងកិច្ចការនារី លោកជំទាវវេជ្ជបណ្ឌិត អ៊ឹងកន្ថា ផាវី ដែលបានចំណាយពេលដ៏មានតម្លៃរបស់លោកជំទាវជួបនឹងក្រុមការងាររបស់យើងខ្ញុំ។ យើងខ្ញុំក៏សូមអរគុណតំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនកម្ពុជាចំពោះការលះបង់ពេលវាលា និងការសំដែងមតិនានា។ ជាពិសេស ក្រុមយើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវឯកអគ្គរាជទូតអូស្រ្តាលី អេនជេលឡា ខកខីរ៉េន និងមន្រ្តីរបស់លោកជំទាវ ដូចជា លោកស្រី រូតស៍ ស្ទូរ៉ាត (អនុប្រធានទូត) លោកស្រី បេនិតា សោមើរីល (លេខាទីមួយផ្នែកសហប្រតិបត្តិការអភិវឌ្ឍន៍) និងលោក បាក់ តូក្យូ និងលោកបណ្ឌិត រស់ ឆាយ (ប្រធានកម្មវិធីជាន់ខ្ពស់) ហើយបើគ្មានការជួយគាំទ្រ របស់ពួកគាត់ទេ បេសកកម្មការងារលើកនេះនឹងមិនអាចទទួលបានជោគជ័យឡើយ។

## សេចក្តីផ្តើម៖ ការវិនិយោគរួមបញ្ចូលគ្នារវាង ពិការភាព និង ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

### *ការប្រេបាច់ចូលគ្នារវាងសកម្មភាពពីក្នុងវិស័យពីរផ្សេងគ្នានឹងជួយឱ្យការគ្រប់គ្រងសកម្មភាពកាន់តែប្រសើរឡើង*

ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី កំពុងអនុវត្តកម្មវិធីរយៈពេលប្រាំឆ្នាំចំនួនពីរផ្សេងគ្នាដែលនឹងត្រូវបញ្ចប់ នៅក្នុងឆ្នាំ ២០១៧ ដោយផ្តោតលើការបញ្ចប់អំពើហិង្សារលើស្រ្តី និងពិការភាពនៅកម្ពុជា៖ ក្នុងនោះទឹកប្រាក់ ១៣,៥ លាន ដុល្លារសម្រាប់កម្មវិធីបញ្ចប់អំពើហិង្សាលើស្រ្តី(EVAW) និង ទឹកប្រាក់ ១០,៤ លានដុល្លារសម្រាប់កម្មវិធី លើកកម្ពស់សិទ្ធិជន ពិការនៅកម្ពុជា (DRIC)។ កម្មវិធីទាំងពីរស្របជាមួយ និងគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្តជាតិរបស់រាជរដ្ឋាភិបាលកម្ពុជារួមមាន ៖ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សារលើស្រ្តីដំណាក់កាលទី ២ និងផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព ។

ការវិនិយោគរបស់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី ទាំងនេះបានចូលរួមចំណែកកំណត់នូវសេចក្តីត្រូវការ នៅកម្ពុជា បំពេញចន្លោះខ្វះខាតខាងថវិកា និងស្របជាមួយនឹងនឹងយុទ្ធសាស្រ្ត ជំនួយរបស់ប្រទេសអូស្រ្តាលីដែលបានដាក់ឱ្យ អនុវត្ត នៅថ្ងៃទី ១៨ មិថុនា ២០១៥៖ ការលើកកម្ពស់វឌ្ឍនភាព ការកាត់បន្ថយភាពក្រីក្រ ការពង្រឹងយុទ្ធសាស្រ្តស្ថិរភាពជំនួយ និងផែនការវិនិយោគជំនួយនៅកម្ពុជាឆ្នាំ ២០១៥-២០១៨ ផងដែរ។ កម្មវិធីទាំងនេះក៏ជាការវិនិយោគដ៏សំខាន់សម្រាប់ ជំរុញការ អនុវត្ត យុទ្ធសាស្រ្តសមភាពយេនឌ័រ និងពិការភាពរបស់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី ថែមទៀត។

ដោយសារដំណាក់កាលវិវត្តិនៃវិស័យទប់ស្កាត់អំពើហិង្សារលើស្រ្តី និងវិស័យពិការភាពមានភាពស្រដៀងគ្នានៅកម្ពុជា និងភាពស្រដៀងគ្នានៃរបៀបគ្រប់គ្រង កម្មវិធី ជំនួយ រួមទាំងកម្មវិធីជំនួយឥតសំណង និង   ភស្តុតាងនៃសេចក្តីត្រូវការសេវាបន្ត ទៀត ដូច្នេះហើយទើបក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី មានគោលបំណងប្រេបាច់សកម្មភាពគ្រប់គ្រងក្នុងវិស័យ ទាំងពីរបញ្ចូលគ្នាទៅជាកម្មវិធីប្រាំឆ្នាំតែមួយថ្មី ដោយផ្អែកលើសមិទ្ធិផលកន្លងមកនៃ ការវិនិយោគក្នុងកម្មវិធីបញ្ឈប់អំពើហិង្សា លើស្រ្តី និងកម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា ។

## បញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍ ការផ្តល់សេវា ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងជនពិការ

### *ស្រ្តីម្នាក់ក្នុងចំណោមស្រ្តី កម្ពុជាប្រាំនាក់ដែលធ្លាប់មានដៃគូ អាយុពី 15-64 ឆ្នាំធ្លាប់រងនូវអំពើហិង្សាលើរាងកាយ ឬអំពើហិង្សាផ្លូវភេទ*

យោងតាមទិន្នន័យប្រេវ៉ាឡង់ថ្មីៗបានបង្ហាញថាស្រ្តីម្នាក់ក្នុងចំណោមស្រ្តីកម្ពុជាប្រាំនាក់ដែលធ្លាប់មានដៃគូអាយុពី 15-64 ឆ្នាំធ្លាប់រងនូវអំពើហិង្សាលើរាងកាយ ឬអំពើហិង្សាផ្លូវភេទ ឬរងនូវអំពើហិង្សាទាំងពីរទម្រង់ពីសំណាក់ដៃគូស្និទស្នាល របស់ខ្លួនក្នុងមួយឆាកជីវិតរបស់គាត់។ ក្នុងនោះ ប្រាំបីភាគរយទទួលរងនូវអំពើហិង្សាក្នុងរយៈពេល ១២ខែចុងក្រោយនេះ។ អត្រាអំពើហិង្សាទាំងពីរទម្រង់មានកម្រិតខ្ពស់នៅតំបន់ជនបទជាងទីក្រុង[1] ។ ស្រ្តីរងគ្រោះជាច្រើនមិនបានស្វែងរកជំនួយ ទេ ដោយសារតែខ្វះសេវាសមស្រប និងតម្រូវការឱ្យមានការចាប់អារម្មណ៍ ចំណេះដឹង និងសមត្ថភាពជាច្រើនផ្សេងទៀត ក្នុងចំណោមអ្នកផ្តល់សេវា។[2]

### *ប្រជាជនកម្ពុជាប្រមាណ ១០% មានការលំបាកផ្នែករាងកាយ ហើយសេចក្តីត្រូវការការព្យាបាលមានកម្រិតខ្ពស់*

ការសិក្សាថ្នាក់ជាតិស្តីអំពីសុខភាព និងប្រជាសាស្រ្តកម្ពុជាបង្ហាញថាប្រមាណ ៩,៥% នៃចំនួនប្រជាជនលើសពី អាយុ ៥ ឆ្នាំ រាយការណ៍ថាមានការលំបាកលើផ្នែកខ្លះនៃរាងកាយ។ ២,១% រាយការណ៍ថាមាន "ការលំបាកខ្លាំង"។[3] ការ សិក្សាប្រជាសាស្រ្តមួយធ្វើឡើងក្នុងឆ្នាំ ២០១៤ លើកុមារអាយុពី ២ ទៅ ៩ ឆ្នាំបានប៉ាន់ប្រមាណថាមានកុមារ ១៥,៦

---

[1] ការសិក្សាថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ជីវិតរបស់ស្រ្តីនៅកម្ពុជា ក្រសួងកិច្ចការនារី។

[2] ប្រភពដូចគ្នាខាងលើ ទំព័រទី ៩៤-៩៥

[3] វិទ្យាស្ថានស្ថិតិជាតិកម្ពុជា, អគ្គនាយកដ្ឋានផ្នែកសុខមាលភាព(២០១៥), វង្វាយសុខមាលភាពនិងប្រជាសាស្រ្តជាតិឆ្នាំ២០១៤។

ភាគរយ មានកម្សោយផ្នែកណាមួយនៃរាងកាយ និងកុមារ ១០,១ ភាគរយ មានពិការភាព។ ការសិក្សានេះរកឃើញថា មានសេចក្ដីត្រូវការក្នុង ការព្យាបាលយ៉ាងខ្លាំង។[4] កម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា គាំទ្រដោយថវិកាដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី នៅតែសមស្របសម្រាប់កម្ពុជា ហើយវាមានដំណើរឆ្ពោះទៅរកការសម្រេចគោលបំណងតាមផែនការ ។ មានតែសមាសធាតុទី ៣ ដែលផ្ដោតការយកចិត្តទុកដាក់លើវិស័យស្ដារលទ្ធភាពពលកម្ម ទេ ដែលជួបបញ្ហាប្រឈមជាបន្តបន្ទាប់ ក្នុងពេលអនុវត្តកម្មវិធី ។ កម្មវិធីនេះទទួលបានផលប្រយោជន៍ពីអនុសាសន៍ ចេញពីការត្រួតពិនិត្យពាក់កណ្ដាលកម្មវិធី ដែលមានការព្រួយបារម្ភទាក់ទងនឹង ប្រសិទ្ធិផល (ភាគច្រើនទាក់ទងនឹងការសម្របសម្រួល) និងនិរន្តរភាព (ការផ្ដោតការយកចិត្តទុកដាក់ខ្លាំងលើជំនួយតាមបែបប្រតិបត្តិការ ជាជាងជំនួយតាមបែបជំរុញឱ្យមានការផ្លាស់ប្ដូរ)។

### *អង្គការមិនមែនរដ្ឋាភិបាល កំពុងបំពេញទៅលើចន្លោះខ្វះខាតក្នុងការផ្ដល់សេវា*

មានបញ្ហាប្រឈមលើសមត្ថភាព និងនិរន្តរភាពក្នុងការផ្ដល់សេវា ឆ្លើយតបទៅនឹងសេចក្ដីត្រូវការ និងវត្ថុបំណងនៃផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីដំណាក់កាលទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ក្នុងនោះរួមមាន៖

- នៅថ្នាក់ជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងកិច្ចការនារី មានធនធានមនុស្សពុំគ្រប់គ្រាន់ដើម្បីបំពេញមុខងារគោលនយោបាយ និងត្រួតពិនិត្យតាមដាន ក៏ដូចជាសេចក្ដីត្រូវការរៀបចំថវិកា ស្នើថវិកា និងការពារសេចក្ដីត្រូវការចំពោះថវិការបស់ខ្លួននៅឡើយ។
- ក្រសួងសាម៉ីទាំងពីរក៏មានបញ្ហាប្រឈមក្នុងការ ជំរុញលើកទឹកចិត្ត ទៅក្រសួងស្ថាប័នពាក់ព័ន្ធផ្សេង ឱ្យបញ្ចូល និងរាយការណ៍ ពីសកម្មភាពនានា ដែលក្រសួងស្ថាប័នពាក់ព័ន្ធទាំងនោះ មានទំនួលខុសត្រូវស្ថិតនៅក្នុងផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីដំណាក់កាលទី ២ និង និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព
- នៅថ្នាក់ក្រោមជាតិ សមត្ថភាពរដ្ឋាភិបាលក្នុងការផ្ដល់សេវាជូនជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសេវា ជនពិការនៅមានកម្រិត ។ បញ្ហាប្រឈមផ្នែកសមត្ថភាព រួមមានការរៀបចំ និងការគ្រប់គ្រងថវិកា និងការត្រួតពិនិត្យផ្នែកបច្ចេកទេស
- អង្គការមិនមែនរដ្ឋាភិបាលនានាបន្តផ្ដល់សេវាជួរមុខជាច្រើន ជាពិសេសនៅទីតាំងតាមជនបទថ្នាក់ក្រោមជាតិ
- បរិយាកាសនយោបាយពាក់ព័ន្ធនឹងការបោះឆ្នោតជាតិដែលឈានជិតមកដល់ (ពាក់កណ្ដាលឆ្នាំ២០១៨) អាចមានបញ្ហាប្រឈមកាន់បន្ថែមទៀតចំពោះការផ្ដល់សេវា និង
- ការចាត់តាំងមុខងារឡើងវិញនៃទំនួលខុសត្រូវរដ្ឋបាលរបស់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ កំពុងឈានទៅមុខ ជាផ្នែកមួយនៃដំណើរការកែទម្រង់វិសហមជ្ឈការនិងវិមជ្ឈការរបស់រាជរដ្ឋាភិបាល ដែលដំណើរការនេះដឹកនាំដោយក្រសួងមហាផ្ទៃ។ ភាពស្មុគស្មាញសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការផ្ដល់សេវានៅថ្នាក់ក្រោមជាតិក្នុងវិស័យទាំងពីរជាលទ្ធផលដែលធ្វើឱ្យដំណើរការនេះមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ។

### **រាជរដ្ឋាភិបាលកម្ពុជា អនុវត្ត កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កិច្ចគាំពារសង្គម**

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចុះ នូវគោលនយោបាយសំខាន់ពីរ ដែលគាំទ្រដល់ការពង្រឹងនូវសេវាប្រកបដោយបរិយាបណ្ណ សម្រាប់ជនពិការ និងជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបំពេញបន្ថែមដល់ យុទ្ធវិធី របស់កម្មវិធី ACCESS ៖

---

[4] Evans P et al. (២០១៤), ការសិក្សាផ្នែកលើចំនួនប្រជាជនទៅលើការកើនឡើងនៃការចុះខ្សោយនិងពិការភាពក្នុងចំណោមកុមារជនជាតិខ្មែរ, ការអភិវឌ្ឍបញ្ចូលគ្នានៃពិការភាព *CBR*, ២៥ (២), ទំព័រ ៥-២០។

- រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នកំពុងអនុវត្ត នូវ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ ដែលសម្របសម្រួលដោយ ធនាគារពិភពលោក (PFMRP) ។ គោលបំណងសំខាន់ រួមមាន ការកសាងជំនឿទុកចិត្ត ផ្នែកថវិកា ការលើកកម្ពស់គណនេយ្យភាពហិរញ្ញវត្ថុ ការកែលម្អតំណភ្ជាប់គោលនយោបាយថវិកា និងការកែលម្អ គណនេយ្យភាពនៃការអនុវត្ត[5] ។ សំណើកម្មវិធី ACCESS នឹងស្របជាមួយនឹង PFMRP ដំណាក់កាលទី 2 ដោយធ្វើ ការគាំទ្រ ទៅលើការសម្របសម្រួលនិងការប្រាស្រ័យទាក់ទង សម្រាប់ការរៀបចំថវិការវាង អង្គភាពអ្នកធ្វើផែនការ អង្គភាពថវិកា និងអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃក្រសួងគោលដៅពាក់ព័ន្ធ ក្រសួងពាក់ព័ន្ធផ្សេងទៀតដែលមានទំនួល ខុសត្រូវអនុវត្ត NAPVAW2 និង NDSP រដ្ឋាភិបាលថ្នាក់ក្រោមជាតិ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) ។
- ក្របខ័ណ្ឌគោលនយោបាយជាតិ គាំពារសង្គម 2016-2025 (SPPF) បានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅ ថ្ងៃទី ២៤ ខែមីនាឆ្នាំ ២០១៧ ។ SPPF នេះមានគោលបំណងដើម្បីរួមចំណែកដល់ការពង្រឹងនិងពង្រីក ការអភិវឌ្ឍ ធនធានមនុស្សព្រមទាំងជំរុញដល់កំណើនសេដ្ឋកិច្ចជាតិ។ SPPFនេះ ជំរុញដល់សុខដមភាព ការផ្តោតការយកចិត្ត ទុកដាក់ និងពង្រឹងគម្រោងឬកម្មវិធីដែលមានស្រាប់ ក្នុងគោលបំណងដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសុគត ភាព នៃប្រព័ន្ធគាំពារសង្គមទាំងមូល។ ACCESS នឹងអាចរួមចំណែក យ៉ាងសំខាន់ដល់ វត្ថុបំណងទាំងឡាយ ដែល មាននៅក្នុង SPPF មានដូចជា ការពង្រឹងកម្មវិធី បណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់គ្រួសារដែលងាយរងគ្រោះ (ជនពិការ) ការរួមចំណែកដល់គោលនយោបាយរបបសន្តិសុខសង្គមរួមទាំងការលើកកម្ពស់សុខុមាលភាពរបស់ជន ពិការ និងការរៀបចំគោលនយោបាយ ជុំវិញប្រតិបត្តិករសន្តិសុខសង្គមទាំងអស់ ។

## មានការគិតគូរអំពីការអភិវឌ្ឍនិងលទ្ធផលនៅចុងបញ្ចប់នៃការវិនិយោគ

ដើម្បីដោះស្រាយចំពោះសេចក្តីត្រូវការដែលបានរកឃើញ និងដើម្បីច្របាច់បញ្ចូល និងសម្របសម្រួលការ គ្រប់គ្រងសកម្មភាព លើវិស័យ ការបបញ្ឈប់អំពើហិង្សារលើស្ត្រី និងពិការភាព **កម្មវិធី កិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព (ACCESS)** ត្រូវបានស្នើឡើង។ ជាតុសំខាន់ៗនៃកម្មវិធីដែលបានស្នើឡើងរួម មាន៖

- ដោយផ្អែកលើមូលដ្ឋាននៃការវិនិយោគមុនៗ កម្មវិធី ACCESS **នឹងបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតលើការ ពង្រឹងនិរន្តរភាពផ្នែកហិរញ្ញវត្ថុ សម្រាប់សេវាប្រកបដោយគុណភាព នៅក្នុងវិស័យទាំងពីរ**។ កម្មវិធីនេះនឹងស្រប ជាមួយនឹងយុទ្ធសាស្ត្រ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជាការធ្វើឱ្យ ប្រសើឡើងនូវប្រព័ន្ធថវិការ ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)[6]. ACCESS នឹង គាំទ្រ ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ជាក្រសួងគោលដៅ) ដើម្បី ទទួលបានការដំឡើងថវិកា (ដោយផ្អែកលើសេដ្ឋកិច្ចដែលកំពុងរីកចម្រើនរបស់កម្ពុជា) ដើម្បីបំពេញភារកិច្ចក្នុង អណត្តិរបស់ខ្លួន ដោយធ្វើការស្របគ្នានឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- សម្រាប់ការផ្តល់សេវា ACCESS **នឹងរកវិធីដើម្បីពង្រឹង ការផ្តល់សេវា ដោយភ្ជាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល កម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារអភិវឌ្ឍន៍ដ៏ទៃទៀត នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ** រួមទាំងការគាំទ្រដល់ ក្រសួងគោលដៅ ក្នុងការផ្តល់សេវា ដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង ជនពិការ ។ យន្ត ការ ផ្តល់ជំនួយឥតសំណងខ្នាតតូច និងការរៀបចំផែនការរួមគ្នា ក្នុងវិស័យនីមួយៗ នឹង ផ្តល់ឱកាសសម្រាប់ធ្វើកិច្ច ការនេះបាន។ ឧទាហរណ៍ ចំពោះ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រសួងកិច្ចការនារី អង្គការក្រៅរដ្ឋាភិបាល និង កម្មវិធី ACCESS នឹងគាំទ្រដល់ការរៀបចំផែនការផ្តល់សេវាស្ថិតក្រោមការដឹកនាំរបស់ក្រសួងកិច្ចការនារី ។ កិច្ចការ នេះនឹងបង្កលក្ខណៈឱ្យ រាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយនឹងអង្គការក្រៅ

---

[5] http://www.mef.gov.kh/pfmrp-2nd-launch.html

[6] http://www.mef.gov.kh/pfmrp.html

រដ្ឋាភិបាល និងស្ថាប័នពហុភាគីផ្សេងៗ អាចទទួលបានថវិកាជំនួយពីរដ្ឋាភិបាលអូស្ត្រាលី សម្រាប់ការអនុវត្តសកម្មភាព ស្របតាមលក្ខ័ណវិនិច្ឆ័យរបស់កម្មវិធី ACCESS ។ លក្ខ័ណថវិការបស់ ACCESS ត្រូវបានគេរំពឹងថានឹងមានតម្រូវការអន្តរវិស័យ ដែលផែនការវិនិយោគថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូល ។ ឧទាហរណ៍ សកម្មភាពគាំទ្រជនពិការ ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

> កម្មវិធី ACCESS **នឹងផ្តោតលើការគាំទ្រ លើវិស័យពិការភាពដើម្បីពង្រឹងបរិយាបណ្ណសេដ្ឋកិច្ចសម្រាប់ជនពិការ រួមទាំងការផ្សារភ្ជាប់ទំនាក់ទំនង ប្រសើជាងមុន រវាងសេវាស្តារនីតិសម្បទា និងបរិយាបណ្ណសេដ្ឋកិច្ច**។ ជាងនេះទៅទៀត កម្មវិធី ACCESS នឹងគាំទ្រការបង្កើតសេវារកការងារ និងមុខរបរសម្រាប់ជនពិការ ដោយផ្អែកលើគំរូជាតិ និងអន្តរជាតិនានាដែលទទួលបានជោគជ័យ។

សេចក្តីព្រាង គោលដៅ និងលទ្ធផលដែលបានស្នើឡើងត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោមនេះ ហើយការពិពណ៌នាលទ្ធផលនៅចុងបញ្ចប់នៃកម្មវិធី និងលទ្ធផលរយៈពេលមធ្យមរបស់កម្មវិធី ACCESS មានដូចខាងក្រោម។

នឹងមានដ្យាក្រាមអំពីពង្រាងលទ្ធផលកម្មវិធី កិច្ចសហប្រតិបត្តិការ កម្ពុជា-អូស្ត្រាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាពនៅ**ឧបសម្ព័ន្ធទី ១** នៃសេចក្តីសង្ខេបរៀបចំវិនិយោគនេះ។

តារាងដែលសង្ខេបលក្ខណៈខុសគ្នាសំខាន់ៗរវាងកម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា និងគម្រោងកម្មវិធី កិច្ចសហប្រតិបត្តិការ កម្ពុជា-អូស្ត្រាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព និងរវាងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកម្មវិធី កិច្ចសហប្រតិបត្តិការ កម្ពុជា-អូស្ត្រាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាពគឺមាននៅក្នុង **ឧបសម្ព័ន្ធទី ២** នៃសេចក្តីសង្ខេបផែនការវិនិយោគនេះ។

| គោលដៅរបស់កម្មវិធី កិច្ចសហប្រតិបត្តិការ កម្ពុជា-អូស្ត្រាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព៖<br>មានការប្រសើរឡើងនូវ និរន្តរភាព នៃសេវាប្រកបដោយ គុណភាព និងបរិយាបណ្ណ | |
|---|---|
| **លទ្ធផលនៅចុងបញ្ចប់ ទី១ ៖<br>មានការកើនឡើងនូវថវិកា សម្រាប់សេវាដល់ជនពិការ និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ** | |
| **លំហូរការងារ** | **លទ្ធផលរយៈពេលមធ្យម** |
| **១.១. ចំពោះ រាជរដ្ឋាភិបាលកម្ពុជា** | ក្រសួងកិច្ចការនារី, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ កាន់តែមានប្រសិទ្ធិភាពក្នុងការរៀបចំ សំណើរ និងការការពារសេចក្តីត្រូវការថវិការបស់គាត់ ពាក់ព័ន្ធនឹងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សារលើស្ត្រីដំណាក់កាលទី ២ និង និងផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព ។ |
| | ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រុមប្រឹក្សាសកម្មភាពជនពិការស្វែងរកការគាំទ្រ កាន់តែមានប្រសិទ្ធិភាព ដើម្បីក្រសួង ស្ថាប័នពាក់ព័ន្ធនានា អនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សារលើស្ត្រីដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព។ |
| **១.២. ចំពោះអង្គការមិនមែនរដ្ឋាភិបាល** | អង្គការមិនមែនរដ្ឋាភិបាលមានប្រភពហិរញ្ញវត្ថុច្រើន និងប្រកបដោយនិរន្តរភាព សម្រាប់ការផ្តល់សេវានានា។ |
| **លទ្ធផលនៅចុងបញ្ចប់ទី ២៖<br>មានការទទួលបានសេវាប្រកបដោយគុណភាពកាន់តែច្រើនឡើងសម្រាប់ជនពិការ និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ** | |
| **២.១. អំពើហិង្សាទាក់ទិននឹងយេនឌ័រ** | មានការកើនឡើងនូវ ការទទួលយក និងការអនុវត្ត នូវបទដ្ឋានដែលមានស្រាប់ សម្រាប់ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ |
| | ក្រសួងកិច្ចការនារី គាំទ្របណ្តាញបញ្ជូន និងសម្របសម្រួល ប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ |
| **២.២. ពិការភាព** | សេវាស្តារនីតិសម្បទា និងការរកការងារធ្វើ គាំទ្រកាន់តែប្រសើដល់បរិយាបណ្ណសេដ្ឋកិច្ចរបស់ជនពិការ ។ |
| | មូលនិធិជនពិការ កាន់តែមានភាពឯករាជ្យក្នុងការគ្រប់គ្រងចាត់ចែងសេវាស្តារនីតិសម្បទា ។ |
| | សេវារកការងារ និងមុខរបរសម្រាប់ជនពិការត្រូវបានបង្កើតឡើង។ |
| **៣. ពហុវិស័យ** | ផែនការវិនិយោគថ្នាក់ក្រោមជាតិលើកកម្ពស់បរិយាបណ្ណសង្គម និងឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ |

## *លទ្ធផលនៅចុងបញ្ចប់ទី១៖ មានការកើនឡើងនូវថវិកា សម្រាប់សេវាដល់ជនពិការ និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ*

លំហូរការងារពីរត្រូវបានស្នើឡើងសម្រាប់លទ្ធផលនេះ ដោយផ្តោតលើការបង្កើនថវិកាសម្រាប់សេវាដល់ជនពិការ និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

### *១.១. លំហូរការងារផ្តោតទៅលើរាជរដ្ឋាភិបាលកម្ពុជា*

លំហូរការងារនេះនឹងផ្តោតលើ**ការកសាងសមត្ថភាពទាំងក្នុងក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីរៀបចំ ធ្វើសំណើ និងការពារសេចក្តីត្រូវការថវិការបស់គាត់** ដើម្បីគាំទ្រការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សារលើស្ត្រីដំណាក់កាលទី ២ និងផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព ។ មានការកំណត់លទ្ធផលរយៈពេលមធ្យមចំនួនពីរដូចខាងក្រោម៖

*លទ្ធផលរយៈពេលមធ្យមៈ ក្រសួងកិច្ចការនារី, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ រៀបចំ ធ្វើសំណើរ និងការការពារសេចក្តីត្រូវការថវិការបស់គាត់ ពាក់ព័ន្ធនឹងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព កាន់តែមានប្រសិទ្ធិភាព*

សកម្មភាពចាំបាច់ដើម្បីសម្រេចបានលទ្ធផលនេះ គឺការពង្រឹងសមត្ថភាពរបស់ក្រសួងស្ថាប័នគោលដៅទាំងពីរដើម្បីអនុវត្តរបៀបវារៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការបង្កើតសហប្រតិបត្តិការណ៍បច្ចេកទេសឱ្យកាន់តែស្អិតរមួត ត្រូវបានផ្តួចផ្តើមឡើងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងគោលដៅ តាមរយៈការគាំទ្រជំនួយបច្ចេកទេស ។ ការគាំទ្រនេះរំពឹងថានឹងនាំទៅរកការបង្កើនសមត្ថភាពកាន់តែប្រសើរឡើង ដើម្បីរៀបចំ ធ្វើសំណើ និងការពារសេចក្តីត្រូវការថវិកា ដើម្បីការផ្តល់សេវាក្រោមយុទ្ធសាស្រ្តទាំងពីរ។ វិធីសាស្រ្តនេះផ្តោតការយកចិត្តទុកដាក់លើ ការគាំទ្រជំនួយបច្ចេកទេស ដើម្បី ការបង្កើត និងការវិភាគទិន្នន័យនិងភស្តុតាងដែលអាចទុកចិត្តបាន ដើម្បីជាមូលដ្ឋានជាក់លាក់ក្នុងការរៀបចំសំណើថវិកា។ ការកសាង ការរៀបចំស្ថាប័នដែលមានស្រាប់ រួមទាំងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបច្ចុប្បន្នប្រចាំការក្នុងក្រសួងជាគោលដៅទាំងពីរ គឺជាការសំខាន់។ ចំណុចនេះនឹងត្រួសត្រាយផ្លូវមួយនាំទៅរកការបង្កើនថវិកាប្រកបដោយនិរន្តរភាព។

*លទ្ធផលរយៈពេលមធ្យមៈ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រុមប្រឹក្សាសកម្មភាពជនពិការស្វែងរកការគាំទ្រ កាន់តែមានប្រសិទ្ធិភាព ដើម្បីក្រសួង ស្ថាប័នពាក់ព័ន្ធនានា អនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព*

ផ្សារភ្ជាប់ជាមួយនឹងលទ្ធផលកន្លងមក ដោយស្របតាមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា និងតាមរយៈការបន្តការវិភាគសេដ្ឋកិច្ចនយោបាយ កម្មវិធី ACCESS នឹងធ្វើការជាមួយក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ **ដើម្បីបង្កើតភស្តុតាងនិងការវិភាគដែលនឹងជួយក្រសួងស្ថាប័នពាក់ព័ន្ធ នានា ដែលមានទំនួលខុសត្រូវស្ថិតនៅក្រោមផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីដំណាក់កាលទី ២ និងផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព។** ទំនងនឹងមានការផ្តោតការយកចិត្តទុកដាក់ជាដំបូងទៅលើក្រសួង សុខាភិបាល។ ការធ្វើបែបនេះនឹងត្រួសត្រាយផ្លូវសម្រាប់ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ បង្កើនតួនាទីជាអ្នកសម្របសម្រួលជាមួយក្រសួងក្រោមស្ថាប័ននានាដែលជួបបញ្ហាប្រឈមក្នុងការអនុវត្តន៍ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាពនោះ ។ ការ កសាងទំនាក់ទំនង និងការបង្កើតនិងការវិភាគទិន្នន័យគឺជាធាតុសំខាន់នៃអភិក្រមនេះ។

## *១.២. លំហូរការងារផ្តោតទៅលើអង្គការមិនមែនរដ្ឋាភិបាល*

ដោយទទួលស្គាល់ថានិរន្តរភាពហិរញ្ញវត្ថុរបស់អង្គការមិនមែនរដ្ឋាភិបាលគឺជាបញ្ហាផ្ទៃក្នុងមួយរបស់អង្គការ លំហូរការងារនេះនឹងជំរុញការបង្កើតឱ្យមាន**ការអភិវឌ្ឍនៃយុទ្ធសាស្រ្ត ពិពិធកម្មថវិកាមួយ ដែលអង្គការមិនមែនរដ្ឋាភិបាល** ជាពិសេសអង្គការក្នុងស្រុកអាចយកទៅអនុវត្តបាន។ យុទ្ធសាស្រ្តនេះនឹងរួមបញ្ចូលទាំង ការរកថវិការពីវិស័យឯកជន រួមទាំងតាមរយៈទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន និងសក្តានុភាពសហគ្រិនភាពសង្គម នៅកម្ពុជា។ ឱកាសនានាអាចកើតមានសម្រាប់ព្រឹត្តិការណ៍កីឡាដែលឧបត្ថម្ភដោយក្រុមហ៊ុន ឬ ការអភិវឌ្ឍនៃយុទ្ធនាការផ្សព្វផ្សាយម៉ាកឃីហោ/ផ្លាកសញ្ញា ដែលបង្ហាញឱ្យឃើញពីការឧបត្ថម្ភរបស់ក្រុមហ៊ុនចំពោះកម្មវិធី ជនពិការឬជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

*លទ្ធផលរយៈពេលមធ្យម៖ អង្គការមិនមែនរដ្ឋាភិបាលមានប្រភពហិរញ្ញវត្ថុច្រើន និងប្រកបដោយនិរន្តរភាព សម្រាប់ការផ្តល់សេវានានា*

ខណៈពេលដែលពិពិធកម្មហិរញ្ញវត្ថុ គឺជាបញ្ហាផ្ទៃក្នុងដ៏សំខាន់របស់អង្គការនោះ លទ្ធផលនេះនឹង**គាំទ្រកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើពិពិធកម្មហិរញ្ញវត្ថុ** ជាពិសេសអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលរដ្ឋាភិបាលអូស្ត្រាលីបានសហការជាមួយ ជាច្រើនឆ្នាំមកហើយ ហើយដែលពួកគាត់នៅបន្តដើរតួយ៉ាងសំខាន់ក្នុងការផ្តល់សេវា។ លទ្ធផលនេះមានគោលបំណងបន្តការផ្តល់សេវា ដែលមានស្រាប់ទាំងនេះ ខណៈមានមូលដ្ឋានីយកម្ម និងពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់និរន្តរភាពរបស់អង្គការមិនមែនរដ្ឋាភិបាល។

*លទ្ធផលនៅចុងបញ្ចប់ ទី ២៖ មានការទទួលបានសេវាប្រកបដោយគុណភាពកាន់តែច្រើនឡើងសម្រាប់ជនពិការ និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ*

នៅក្នុងលទ្ធផលនេះ នឹងមានលំហូរសកម្មភាពពីរដែលផ្តោតទៅលើក្រុមគោលដៅពីរ (ជនពិការ និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ) ។ សកម្មភាពនៅក្រោម លទ្ធផលចុងបញ្ចប់ទី២ នេះ អាចនឹងពង្រីកដោយរួមបញ្ចូលក្រុមគោលដៅផ្សេងទៀត ប្រសិនបើមានថវិកា។ មានសំណើ ឱ្យមាន**ការផ្តោតការយកចិត្តទុកជាដំបូង លើវិស័យសុខាភិបាល** ចំពោះលំហូរទាំងពីរ។ ទាំងនេះ ដោយផ្អែកទៅលើភាពដូចគ្នាខាងផ្នែកបច្ចេកទេស និងសមិទ្ធិផលដែលបានមកពីការវិនិយោគមុនៗនៃកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកម្មវិធីលើកម្ពស់សិទ្ធិជនពិការនៅកម្ពុជា រួមទាំងផ្តល់ឱកាសក្នុងការបំពេញផលប្រយោជន៍ទៅវិញទៅមកតាមរយៈ កម្មវិធីវិនិយោគនៅក្នុងវិស័យសុខាភិបាលរបស់អូស្ត្រាលី ដូចជាគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល (H-EQIP) ។

*២.១. លំហូរការងារ ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ*

ខណៈដែលការយកចិត្តទុកដាក់ផ្តោត លើសេវា អភិក្រមទូទៅ និងលក្ខខ័ណ្ឌសម្រាប់ស្ថាប័នទទួលជំនួយ នឹង**សង្កត់ធ្ងន់លើ ការដាក់បញ្ចូលនៃគោលការណ៍បង្ការ**។ ចំណុចនេះគឺរួមទាំងការបង្ការបឋម ដូចជាតួនាទីរបស់អ្នកផ្តល់សេវាក្នុងការកែប្រែបទផ្នត់គំនិតសង្គមជុំវិញការទទួលយក និងការពឹងអាស្រ័យលើអំពើហិង្សា  និងការបង្ការដំណាក់កាលទីពីរ ដោយសារតួនាទីនៃសេវានៅក្នុងការបង្ការ កុំឱ្យមានឧប្បត្តិហេតុបន្ថែមទៀត។

*លទ្ធផលរយៈពេលមធ្យម៖  មានការកើនឡើងនូវ ការទទួលយក និងការអនុវត្ត នូវបទដ្ឋានដែលមានស្រាប់ សម្រាប់ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ*

ចំនុចនេះនឹងផ្តល់អាទិភាពលើ ការផ្តល់សេវាចំនួនពីរចំណុច៖

**វិស័យសុខាភិបាល៖ ការប្រឹក្សាយោបល់ និងការគាំទ្រខាងចិត្តសង្គម** ដូចមានចែងនៅក្នុង បទដ្ឋានអប្បបរិមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រី ដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី ២០១៦) និងតួនាទីនៃសេវាសុខភាព ដូចមានចែងនៅក្នុងគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងអំពើហិង្សាលើស្ត្រី នៅក្នុងសៀវភៅណែស្តីពីការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទស្នាល ឬអំពើហិង្សាផ្លូវភេទ (ក្រសួងសុខាភិបាល ២០១៦)។

**យុត្តិធម៌៖** ការអនុវត្តគោលការណ៍ណែនាំ ដែលនឹងអនុម័តនាពេលខាងមុខស្តី ពីការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ (រំពឹងថានឹងអនុម័តនៅឆ្នាំ២០១៧) ឯកសារនេះនឹងជាជំនួយផ្លូវច្បាប់ និងអាចជួយពង្រឹងតួនាទីរបស់ភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី ។ ចំណុចនេះមិនបានស្នើឱ្យធ្វើការលើសពីនេះជាមួយវិស័យយុត្តិធម៌ផ្លូវការទេ។

អាចមានការគាំទ្រលើសេវាផ្សេងៗទៀតដែរ យោងទៅតាមដំបូន្មានរបស់ក្រសួងកិច្ចការនារី និងតាមការពិចារណាលើសេចក្តីត្រូវការនៃការបញ្ជូនជាក់ស្តែង (សូមអានលទ្ធផលខាងក្រោម)។

*លទ្ធផលរយៈពេលមធ្យម៖ ក្រសួងកិច្ចការនារី គាំទ្របណ្តាញបញ្ជូន និងសម្របសម្រួល ប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ*

សកម្មភាពនៅក្នុងលទ្ធផលនេះ **នឹងផ្តោតការយកចិត្តទុកដាក់លើតួនាទីរបស់ក្រសួងកិច្ចការនារីក្នុងការអភិវឌ្ឍន៍សមត្ថភាពបណ្តាញ ទំនាក់ទំនង និងការប្រតិបត្តិទៅតាមគោលការណ៍ណែនាំក្នុងការបញ្ជូន**ស្រ្តី និងកុមារីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ក្រសួងកិច្ចការនារី ២០១៦)។ ការងារនេះនឹងបំពេញបន្ថែមទៅលើ កម្មវិធី ទទួលបានយុត្តិធម៌សម្រាប់ស្រ្តីដំណាក់កាលទី ២ (ATJW2) ដែលជារបៀបអនុវត្តកម្មវិធីក្នុងសហគមន៍ អនុវត្តន៍ដោយ ទីភ្នាក់ងារ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ)។ គោលបំណងនេះនឹងត្រូវបំពេញទៅលើ មជ្ឈមណ្ឌលផ្តល់សេវាចម្រុះ **(virtual one-stop service centre model )** ដែលផ្តួចផ្តើមដោយក្រសួងកិច្ចការនារី។ វាត្រូវបានគេពឹងទុកថាសេវា នឹងត្រូវបានពង្រីកដោយផ្អែកលើ ការសិក្សាម៉ត់ចត់ទៅលើ ទីតាំងនៃសេវាដែលអាចរកបាន និងតម្រូវការ។ មន្ទីរកិច្ចការនារី) PDoWA) និងគណៈកម្មាធិការ ឃុំ ស្រុក/ខណ្ឌ រាជធានី/ខេត្ត សម្រាប់ស្រ្តី និងកុមារ) PCWC, DCWC និង CCWC) គឺភាគីពាក់ព័ន្ធដ៏សំខាន់ ទាក់ទងទៅនឹងលទ្ធផល នេះ។ នឹងមានឱកាសក្នុងការ ភ្ជាប់កម្មវិធី ប៉ូលីសសហគមន៍ (Community Policing Initiative)ដែលគាំទ្រដោយ រដ្ឋាភិបាលអូស្រ្តា និងភ្នាក់ងារប៉ូលីស និងភ្នាក់ងារនិងមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី ។

## *២.២.លំហូរការងារពិការភាព*

*លទ្ធផលរយៈពេលមធ្យម៖ សេវាស្តារនីតិសម្បទា និងការរកការងារធ្វើ គាំទ្រកាន់តែប្រសើរដល់បរិយាបណ្ណសេដ្ឋកិច្ចរបស់ជនពិការ*

ត្រូវបានស្នើឱ្យចាប់ផ្តើម**ធ្វើការងារលើ បរិយាបណ្ណសេដ្ឋកិច្ច ដោយផ្តោតការយកចិត្តទុកដាក់លើជនពិការ។** អាចមានឱកាសក្នុងការពង្រីកសកម្មភាពការងារនៅក្រោម លទ្ធផលនេះ ទៅដល់ការលើកស្ទួយសេដ្ឋកិច្ចដល់ជនរងគ្រោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្រ្តីជាទូទៅ ឬជនងាយរងគ្រោះ ពិសេសប្រសិនបើមានថវិកាបន្ថែម។ **ការផ្តោតការយកចិត្តទុកដាក់ ជាបឋម គឺទៅលើបរិយាបណ្ណសង្គមតាមរយៈការស្តារនីតិសម្បទា រួមមានអវយវៈសិប្បនិម្មិត និងឧបករណ៍ជំនួយផ្សេងទៀត និងការផ្តល់ឱកាសការងារជាផ្លូវការ តាមរយៈការស្វែងរកការងារឱ្យធ្វើ និងបញ្ច្រាបការយល់ដឹងនៅកន្លែងការងារ រួមទាំងការពង្រឹងសមត្ថភាពរបស់ជនពិការក្នុងការត្រៀមខ្លួនរកការងារធ្វើ** ។ នឹងមានការបើកចំហរឱ្យមានការលើកកម្ពស់សហគ្រិនភាពសម្រាប់ជនពិការ ឬ សហគ្រិនភាពពាក់ព័ន្ធនឹងជនពិការ ប៉ុន្តែ នឹងផ្តោតការយកចិត្តទុកដាក់តែទៅលើ ការគាំទ្រសហគ្រាសណាដែលថវិការមានលក្ខណៈ សមស្រប និងមាននិរន្តរភាពតែប៉ុណ្ណោះ។ កម្មវិធី ACCESS នឹងមិនគាំទ្រសកម្មភាពផ្តល់ជំនួយខ្នាតតូច ឬប្រាក់កម្ចី ឬ កម្មវិធីមុខរបរដែលមានឆន្ទៈល្អ ប៉ុន្តែមិនមានផែនការច្បាស់លាស់ ឬមុខរបរដែលផ្អែកលើជំនាញកម្រិតទាប និងគ្មានបណ្តាញទីផ្សារច្បាស់លាស់។

*លទ្ធផលរយៈពេលមធ្យម៖ មូលនិធិជនពិការ កាន់តែមានភាពឯករាជ្យក្នុងការគ្រប់គ្រងចាត់ចែងសេវាស្តារនីតិសម្បទា*

សកម្មភាពនៅក្រោមលទ្ធផលនេះគឺនឹង **កសាងភាពត្រៀមខ្លួនរួចជាស្រេចរបស់ កិច្ចការគ្រប់គ្រង ដើម្បីសេវាប្រកបដោយគុណភាពនិងនិរន្តរភាព ដោយផ្អែកលើផែនការផ្ទេរសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនមូលនីធិជនពិការ ដែលសព្វថ្ងៃ កំពុងដំណើការដោយមានការឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។** សេវាលទ្ធភាពពលកម្មកាយសម្បទាត្រូវបានចាត់ជាអាទិភាពដោយសារវាមានតួនាទីដ៏សំខាន់ក្នុងការបង្កើតបរិយាបណ្ណសេដ្ឋកិច្ចនិងសង្គមរបស់ជនពិការ និងក្នុងការផ្តល់ការគាំទ្រផ្នែកសង្គម និងផ្លូវចិត្តដល់ជនពិការនិងគ្រួសារពួកគាត់។ មានបណ្តាញ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាដែលមានស្រាប់ ចំនួន១១ និងមជ្ឈមណ្ឌលរបួសខួរឆ្អឹងខ្នងចំនួនមួយ រោងចក្រផលិតឧបករណ៍សិប្បនិម្មិត និងរណបចំនួនមួយ និងរោងជាងជួសជុលឧបករណ៍សិប្បនិម្មិត និងរណប ចំនួនបីកន្លែង ដែលនឹងគាំទ្រនៅ ក្រោមលទ្ធផលនេះ។

*លទ្ធផលរយៈពេលមធ្យម៖ សេវារកការងារ និងមុខរបរសម្រាប់ជនពិការត្រូវបានបង្កើតឡើង*

នេះគឺជាការគាំទ្រ សកម្មភាពសិក្សាថ្មី របស់កម្មវិធីនេះ ហើយដូច្នេះរបៀបអនុវត្តច្រើនយ៉ាងនឹងត្រូវធ្វើឡើង ។ ការផ្តោតការយកចិត្តទុកដាក់ជាបឋមគឺទៅលើ **ការបង្កើតសេវាស្វែងរកការងារ ដោយផ្សារភ្ជាប់ជនពិការជាមួយ ឱកាសការងារផ្លូវការនានា។** សកម្មភាពនៅត្រង់លទ្ធផលនេះ នឹងគាំទ្រវត្ថុបំណងក្នុងការលុបបំបាត់ការមាក់ងាយ និងការរើសអើងចំពោះជនពិការ ដែលស្វែងរកការងារធ្វើ។

## *៣. លំហូរការងារពហុស័យ*

*លទ្ធផលរយៈពេលមធ្យម៖ ផែនការវិនិយោគថ្នាក់ក្រោមជាតិលើកកម្ពស់បរិយាបណ្ណសង្គម និងឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ*

នឹងមានការផ្តល់ជំនួយឥតសំណងគាំទ្រថវិកាដល់អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអន្តរជាតិ និងដៃគូដ៏ទៃទៀតក្នុងវិស័យ ទាំងពីរ ដើម្បីផ្សារភ្ជាប់ និងជំរុញដល់ ផែនការវិនិយោគឃុំ ព្រមទាំងភ្ជាប់ទៅនឹងគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ សកម្មភាពរំពឹងទុករួមមាន ការកាត់បន្ថយកត្តាហានិភ័យ ដែលទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូចជាការប្រើប្រាស់គ្រឿងស្រវឹង។ មានការស្នើឡើងផងដែរថាកម្មវិធីនេះគាំទ្រដល់ការអភិវឌ្ឍ នៃវិធីសាស្រ្តសំរបសំរួលបន្ថែមទៀត និងការគាំទ្រផ្តល់ឯកសា/សម្ភារៈ ដើម្បីកសាងចំណេះដឹងក្រុមប្រឹក្សាឃុំ និងការប្តេជ្ញា ក្នុងការបរិយបណ្ណសង្គម ជាពិសេសសម្រាប់ជនពិការ។ ដោយការទទួលយកវិធីសាស្រ្ត គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធី ACCESS នឹងធ្វើការជាមួយ ក្រសួងកិច្ចការនារី មន្ទីកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីយល់កាន់តែច្បាស់ ព្រមទាំងជំរុញដល់ការធ្វើផែនការថវិកាថ្នាក់ខេត្ត និងថ្នាក់ស្រុក ដើម្បីជំរុញដល់បរិយាបណ្ណក្នុងសង្គម ជាពិសេសសម្រាប់ជនពិការ និងការឆ្លើយតបសមស្របទៅនឹងអំពើហិង្សាយេនឌ័រ។ ចំនុចនេះនឹងតម្រូវឱ្យមានទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ (NCDD) ដែលជាអ្នកតស៊ូមតិសំខាន់ពីរនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

## **អភិក្រមអនុវត្តកម្មវិធី និងដៃគូសំខាន់ៗ**

*កម្មវិធី ACCESS នឹងចាប់យកវិធីសាស្រ្ត បំពេញបន្ថែម (accompaniment)*

*កម្មវិធី ACCESS នឹងចាប់យកវិធីសាស្រ្ត បំពេញបន្ថែម (ដំណើរការនៃការផ្តល់ទីប្រឹក្សា និងគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាព) ដូចខាងក្រោម៖*

- ការគាំទ្រដល់ដំណើរការធ្វើផែនការ របស់ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផ្តល់អាទិភាពដល់ការ ផ្តល់សេវា។ ឧទាហរណ៍ ការកំណត់ភូមិសាស្រ្តនៃកម្មវិធីនេះ នឹងត្រូវបានកំណត់ដោយ មានការពិគ្រោះយោបល់ជាមួយក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងពិចារណាលើតម្រូវការនិង សេវាដែលមានស្រាប់ ដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលនិងរដ្ឋាភិបាល
- ការជ្រើសរើសតំបន់គោលដៅដើម្បីអនុវត្តសកម្មភាព នឹងត្រូវបានផ្តោតដោយអាស្រ័យលើ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលអូស្រ្តាលី ដោយរួមគ្នាពិចារណាលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសតំបន់គោលដៅ។ លក្ខណៈវិនិច្ឆ័យទាំងនេះអាចរួមបញ្ចូលទាំង ការតភ្ជាប់ទៅនឹងសកម្មភាពដែលទទួលធ្លាប់ទទួលបានថវិការបស់អូស្រ្តាលីពីមុន (EVAW / DRIC ឬកម្មវិធីផ្សេងទៀត - ឧទាហរណ៍ CPI) ការបង្កើតទំនាក់ទំនងជាមួយអាជ្ញាធរនិងភាគីពាក់ព័ន្ធ ទិន្នន័យដែលកើតមានអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទិន្នន័យសហគមន៍ (ស្រ្តី កុមារ និងជនពិការដែលជាជនងាយរងគ្រោះ និងជនជាតិភាគតិច)

- នៅថ្នាក់ជាតិ កម្មវិធី ACCESS នឹងជួយពង្រឹងសមត្ថភាពរបស់ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីធានា និងប្រតិបត្តិថវិកា ក្នុងគោលបំណងធានាគុណភាពសេវា និងដើម្បីគាំទ្រដល់ក្រសួងពាក់ព័ន្ធផ្សេងទៀត នៅក្នុងកិច្ចខិតខំប្រឹងប្រែងដូចគ្នានេះ
- កម្មវិធី ACCESS នឹងធ្វើការជាមួយរដ្ឋាភិបាលថ្នាក់ក្រោមជាតិ (បើអាចធ្វើទៅបានសម្របជាមួយនឹងគោលនយោបាយថ្នាក់ជាតិ) ដើម្បីកែលម្អការផ្តល់សេវា ពិសេសតាមរយៈ ការលើកកម្ពស់ការយល់ដឹង និងការសម្របសម្រួលនៃការផ្តល់សេវា។

កម្មវិធីនេះនឹងរួមបញ្ចូល យន្តការប្រគួតប្រជែងយកថវិការ (Grants) ដោយមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់។ Grant រំពឹងថានឹងមានរយៈពេលវែង ដែលមានពីរដង ក្នុងកម្មវិធីនេះ (ឆ្នាំទី 1 និងឆ្នាំទី 3) ។ សកម្មភាពជាក់លាក់ ដែលបានជ្រើសនិងអ្នកជំនាញបច្ចេកទេស នឹងត្រូវបានគេដាក់ដេញថ្លៃ

## *អភិបាលកិច្ចកម្មវិធី*

មានការស្នើឡើងនូវ គណៈកម្មាការអន្តរក្រសួង រួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី (គណកម្មាការដឹកនាំរួម របស់កម្មវិធី ACCESS (ASC)) ដែលមានតំណាងមកពីក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (ទីប្រឹក្សាអភិវឌ្ឍន៍ ឬអ្នកមានតួនាទីស្មើគ្នា) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានក្រុមកម្មវិធីACCESS (អ្នកម៉ៅការអនុវត្តគម្រោង។

ក្រុមអ្នកគ្រប់គ្រង កម្មវិធី ACCESS និង បុគ្គលិកបច្ចេកទេស និងតំណាងពីអង្គការក្រៅរដ្ឋាភិបាលនិងអង្គការអន្តរជាតិអាចនឹងត្រូវបានអញ្ជើញឱ្យចូលរួមផ្តល់យោបល់ ។ វាត្រូវបានស្នើឡើងថា ASC នឹងជួបប្រជុំយ៉ាងហោចណាស់ ជារាងរាល់ ប្រាំមួយខែម្តង ដើម្បីផ្តល់នូវការណែនាំជាយុទ្ធសាស្ត្រ និងពិនិត្យទៅលើវឌ្ឍនភាពនៃកម្មវិធី។ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជានឹងពិនិត្យ និងយល់ព្រមលើការរៀបចំដំណើរការនៃ ASC នេះ។

## *ការទទួលបាន ថវិកាតាមរយៈ យន្តការជំនួយឥតសំណង និងការតាមដានវឌ្ឍនភាព*

ក្រសួង (និងវិស័យ) គោលដៅនីមួយៗជួបប្រជុំដើម្បីរៀបចំផែនការ និងរៀបចំសំណើរសកម្មភាពសម្រាប់ទទួលថវិកាតាមរយៈយន្តការ Grants Mechanism របស់កម្មវិធី ACCESS ។ កម្មវិធីស្នើប្រតិបត្តិករនៃក្រសួនិមួយៗដឹកនាំកិច្ចប្រជុំនេះ។ ដំណើរការនៃការរៀបចំផែនការរួមគ្នានឹងជំរុញឱ្យក្រសួងគោលដៅ និងអង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារអន្តរជាតិផ្សេងទៀតមានឱកាសធ្វើការជាមួយគ្នា ដើម្បីរៀបចំសកម្មភាពដែលឆ្លើយតបទៅនឹងលក្ខខ័ណ្ឌវិនិច្ឆ័យថវិការបស់កម្មវិធី ACCESS ។ នឹងមានគម្រោងសំណើរពីរដង៖ ឆ្នាំទី១ (សម្រាប់ឆ្នាំទី១-៣) និងឆ្នាំទី៣ (សម្រាប់ឆ្នាំទី៤ និង៥)។ ស្ថាប័នទទួលថវិកា (អ្នកអនុវត្តសកម្មភាព) នឹងអាចជាអង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងវិស័យឯកជន។ កិច្ចព្រមព្រៀងដោយឡែកនឹងត្រូវបានអនុវត្តចំពោះថវិកា ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលីបែងចែកសម្រាប់ទីភ្នាក់អង្គការសហប្រជាជាតិដោយស្របជាមួយនឹងដំណើរការនៃការសម្រេចចិត្តនេះ។

គណៈកម្មាការ Grants របស់កម្មវិធី ACCESS (AGP) និង ពិនិត្យទៅលើគម្រោងសំណើរដែលរៀបចំតាមរយៈដំណើរការនៃការរៀបចំផែនការរួមគ្នានេះ និងសម្រេចចិត្តទៅលើថវិកាជំនួយ។ សមាជិកគណៈកម្មាការ AGP រួមមាន៖ លេខាទី១ ស្ថានទូតអូស្ត្រាលី ផ្នែកសហប្រតិបត្តិការអភិវឌ្ឍន៍ ដំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកម៉ៅការ និងសមាជិកឯករាជ្យម្នាក់ចេញពីអង្គការក្រៅរដ្ឋាភិបាល ឬវិស័យឯកជន។

### *ការគ្រប់គ្រងការអនុវត្ត*

រដ្ឋាភិបាលអូស្ត្រាលីនឹងធ្វើលទ្ធកម្មឱ្យអ្នកម៉ៅការគ្រប់គ្រងអនុវត្តកម្មវិធី ACCESS រួមទាំងការជ្រើសរើស និងគ្រប់គ្រងបុគ្គលិកបច្ចេកទេសជាតិ និងអន្តរជាតិរយៈពេលខ្លី និងរយៈពេលវែង ដើម្បីបំពេញបន្ថែម សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃ រាយការណ៍

អំពីការអនុវត្ត និងលទ្ធផល និងត្រួតពិនិត្យថវិកាជំនួយ។ កម្មវិធីនឹងជ្រើសរើបុគ្គលិកបច្ចេកទេសដែលមានជំនាញផ្នែកពិការភាព អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### *ការតាមដានត្រួតពិនិត្យ វាយតម្លៃ និងការសិក្សា*

កម្មវិធីនឹងអនុវត្តនូវយុទ្ធសាស្ត្ររួមបញ្ចូលគ្នាអំពីរបៀបតាមដានត្រួតពិនិត្យ វាយតម្លៃ និងការសិក្សា (MEL) ដើម្បីបង្កើតទិន្នន័យដែលចូលរួមក្នុងការរៀបចំផែនទីសេវា និងគណនេយ្យភាពសង្គម។ វិធីសាស្ត្រនេះអាចបញ្ចូលសូចនាកររួមសម្រាប់ស្ថាប័នទទួលថវិកាទាំងអស់ដែលមានទំនាក់ទំនងជាមួយផែនការយុទ្ធសាស្ត្រជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ តម្រូវការនេះនឹងមានលក្ខណៈបន្ទាបបន្សំដោយស្ថាប័នទទួលថវិកាប្រើប្រាស់នូវប្រព័ន្ធផ្ទាល់ខ្លួនដើម្បីបង្កើតទិន្នន័យ។ MELរួមមានការបង្កើតករណីសិក្សាដែលនឹងអាចប្រើជាឧបករណ៍ទំនាក់ទំនងសម្រាប់អនុវត្តទីតាំងផ្សេងទៀត។ ស្ថាប័នទទួលថវិកានឹងត្រូវប្រមូលទិន្នន័យអំពីករណីថ្មីៗខណៈដែលកំពុងអនុវត្តសកម្មភាពនៅក្នុងសហគមន៍។ MEL នឹងរួមបញ្ចូលដំណើរការនៃការផ្តល់ព័ត៌មានត្រឡប់ទាក់ទងនឹងផែនការប្រចាំឆ្នាំ។ ការពិនិត្យឡើងវិញនូវថវិកាជំនួយនឹងធ្វើឡើងនៅក្នុងឆ្នាំទី៣ រួមជាមួយនឹងការរំពឹងថានឹងធ្វើការពិនិត្យឡើងវិញទ្រង់ទ្រាយតូចនៅជុំចុងក្រោយ ។

កម្មវិធី ACCESS នឹងរៀបចំរបាយការណ៍វឌ្ឍនៈភាព និងរបាយការណ៍ហិរញ្ញវត្ថុជារៀងរាល់៦ខែម្តង រួមទាំងរបាយការណ៍លទ្ធផលសកម្មភាពដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលកម្ពុជា និងអូស្ត្រាលី។ របាយការណ៍វឌ្ឍនៈភាព និងរបាយការណ៍សកម្មភាពអាចនឹងផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធរបស់កម្មវិធី ACCESS ប្រសិនបើអាចធ្វើទៅបាន។

## ហានីភ័យចំបងៗ និងបញ្ហាប្រឈម

- **តម្រូវការលើសមត្ថភាព ធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស៖** មានហានិភ័យមួយគឺថាកិច្ចការកសាងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងក្រសួងគោលដៅ ស្របពេលជាមួយនឹងការកសាងសមត្ថភាពក្នុងការផ្តល់សេវា សម្រាប់ជនពិការ និងជនរងគ្រោះដោយអំពើហិង្សា នឹងជាបន្ទុកផ្នែកធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស របស់ក្រសួងគោលដៅ។ ចំនុចនេះ អ្នកម៉ៅការគ្រប់គ្រងកម្មវិធី នឹងត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងគោលដៅ ដើម្បីកំណត់អត្តសញ្ញាណគោលដៅប្រាកដនិយម ទាញយកប្រយោជន៍ពីឱកាស និងដើម្បីកសាងប្រព័ន្ធ MEL ដើម្បីគាំទ្រដល់ការធ្វើការសម្រេចចិត្តសមស្រប។
- **របៀបធ្វើការដាច់ដោយឡែកពីគ្នា ធ្វើឱ្យខាតបង់ការវិនិយោគ៖** អវត្តមាននៃកិច្ចព្រមព្រៀងជាមុននូវទិសដៅនិងផែនទីរបស់កម្មវិធីអាចធ្វើឱ្យខាតបង់នូវការវិនិយោគរបស់អូស្ត្រាលីក្នុងកម្មវិធីនេះ និងកម្មវិធីរបស់អូស្ត្រាលីផ្សេងទៀតដូចជា CPI ។ ចំនុចនេះ អ្នកម៉ៅការគ្រប់គ្រងកម្មវិធី នឹងគាំទ្រដល់ការពិនិត្យ សំណើតាមរយៈការផ្តល់ការគាំទ្របច្ចេកទេស ទៅដល់ក្រសួងគោលដៅ និងអង្គការក្រៅរដ្ឋាភិបាល និងតាមរយៈជំនួយបច្ចេកទេសដើម្បីរៀបចំ គោលការណ៍ណែនាំគម្រោងសំណើ ក្នុងគោលបំណង បង្កើននូវកិច្ចសហប្រតិបត្តិការ និងឱកាស ដើម្បីជំរុញឱ្យមានលទ្ធផលប្រសើររួមគ្នា ។
- **ការបែងចែកថវិកាជាតិ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ ការផ្តល់សេវាផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនពិការមិនមានការកើនឡើង៖** ក្រៅពីកម្មវិធីវិនិយោគ និងកិច្ចខិតខំប្រឹងប្រែងអស់ពីលទ្ធភាពនេះ ការបែងចែកថវិកាជាតិ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ ការផ្តល់សេវាដោយបរិយាបណ្ណអាចនៅតែមិនមានការកើនឡើង ដោយបន្ទុកថវិកានៅតែបន្តធ្លាក់ទៅលើសហគមន៍អ្នកផ្តល់ជំនួយ។ ចំនុចនេះអ្នកម៉ៅការគ្រប់គ្រងកម្មវិធី នឹងត្រូវរៀបចំយុទ្ធសាស្ត្រមួយដែលពង្រីកឥទ្ធិពលរបស់កម្មវិធីនេះ នៅលើការវិភាជន៍ថវិកា រួមបញ្ចូលទាំងជំនួយបច្ចេកទេសដល់ផ្នែកហិរញ្ញវត្ថុកម្រិតខ្ពស់ ។ ចំនុចនេះ ក៏នឹងត្រូវការ ការវិភាគសេដ្ឋកិច្ចនយោបាយលម្អិត ដើម្បីរៀបចំយុទ្ធសាស្ត្រនេះ។ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និងអ្នកសកម្មដ៏ទៃទៀតនៅក្នុងវិស័យទាំងពីរ នឹងត្រូវជំរុញយ៉ាងសកម្ម រួមទាំងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ។

- ការបោះឆ្នោតដែលនឹងខិតជិតមកដល់ អាចរំខានដល់វឌ្ឍនភាពរបស់កម្មវិធី៖ ការបោះជាតិដែលនឹងប្រារព្ធឡើងនៅឆ្នាំ ២០១៨ អាចជាហានិភ័យ ដែលអាចរំខានដល់ការអនុវត្តកម្មវិធី។ អូស្ត្រាលីនឹងអង្កេតបរិយាកាសនយោបាយ ដើម្បីកំណត់នូវហានិភ័យទាន់ពេលវេលាក្នុងការសម្របសម្រួលទិសដៅកម្មវិធី ប្រសិនបើចាំបាច់ ។ ចំនុចនេះអ្នកម៉ៅការគ្រប់គ្រងកម្មវិធី នឹងត្រូវរៀបចំឯកសារផែនការគ្រប់គ្រងហានិភ័យឱ្យមានរួចជាស្រេច ។

## កាលវិភាគសម្រាប់ការចូលរួមនិងធនធាន

- ថវិកា ២៥លានដុល្លាអូស្ត្រាលី សម្រាប់រយៈពេល ប្រាំឆ្នាំកន្លះ ត្រូវបានស្នើឡើង។ កម្មវិធីនេះនឹងចាប់ផ្តើមនៅក្នុងត្រីមាសទីមួយនៃឆ្នាំ ២០១៨ និងដំណើការរហូតដល់ ថ្ងៃទី ៣០ មិថុនា ឆ្នាំ២០២៣។
- អាស្រ័យដោយកម្មវិធី ACCESS បន្តពង្រឹងទៅលើកម្មវិធីវិនិយោគរបស់អូស្ត្រាលីមុនៗនៅកម្ពុជារួមទាំងបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូរាជរដ្ឋាភិបាលដែលមានស្រាប់នោះ កម្មវិធីវិនិយោគនេះចាត់ទុកថាមានហានីភ័យកម្រឹតទាប។
- ពង្រាង Program Logic របស់កម្មវិធី ACCESS ត្រូវបានកំណត់ចេញនៅទំព័រមួយចំហៀងទៀត។
- តារាងដែលបង្ហាញពីចំនុចខុសគ្នា រវាងកម្មវិធីមុនៗ (DRIC និង EVAW) និងកម្មវិធី ACCESS អនុវត្តតាមគំរូ Program Logic នេះ ។

## ឧបសម្ព័ន្ធទី ១៖ គំរូ Program Logic នៃកម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលី ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព

## គោលដៅ៖ មានការប្រសើរឡើងនូវ និរន្តរភាព នៃសេវាប្រកបដោយ គុណភាព និងបរិយាបណ្ណ



## ឧបសម្ព័ន្ធទី ២៖ ការប្រៀបធៀបរវាងកម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជានិងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលីដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព

### ចំណុចខុសគ្នាសំខាន់ៗរវាងកម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា និងកម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលីដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព

| | **កម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា (DRIC)** | **កម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលីដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព (ACCESS)** |
|---|---|---|
| គំរូ | អនុវត្តដោយទីភ្នាក់ងារអង្គការសហប្រជាជាតិចំនួន ៣ | ការអនុវត្តទាំងអស់នឹងគ្រប់គ្រងដោយ ក្រុមអ្នកម៉ៅការគ្រប់គ្រងកម្មវិធី (ថវិកាជំនួយ ការដេញថ្លៃ និងជំនួយបច្ចេកទេស) |
| ដៃគូអនុវត្ត | ដៃគូគ្រប់គ្រងកម្មវិធី DRIC៖<br>– ទីភ្នាក់អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍអន្តរជាតិ មូលនីធិកុមារអង្គការសហប្រជាជាតិ និងអង្គការសុខភាពពិភពលោក<br>ដៃគូអនុវត្តសំខាន់ៗ៖<br>– អង្គការជនពិការកម្ពុជា ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងមូលនីធិជនពិការ<br>– ស្ថាប័នទទួលថវិកាជំនួយផ្តល់សេវាចំនួន ១៥ | នឹងកំណត់បានតាមរយៈដំណើរការប្រកួតប្រជែងទទួលបានថវិកាជំនួយ និងការដេញថ្លៃ |
| គោលដៅ | ធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ជនពិការ | មានការប្រសើរឡើងនូវ និរន្តរភាព នៃសេវាប្រកបដោយ គុណភាព និងបរិយាបណ្ណ ក្នុងនោះរួមមានការស្តារលទ្ធភាពពលកម្មកាយសម្បទា ការទទួលបានទីផ្សារការងារសម្រាប់ជនពិការ និងសេវាមួយចំនួនទៀតពាក់ព័ន្ធនឹងជនពិការ។ ពេលចប់កម្មវិធី ACCESS រាជរដ្ឋាភិបាលគួទទួលជំនួសនូវ ទំនួលខុសត្រូវហិរញ្ញវត្ថុយ៉ាងច្រើនសម្រាប់ការផ្តល់សេវា ។ |
| គោលបំណង | គាំទ្ររាជរដ្ឋាភិបាលកម្ពុជាធ្វើឱ្យប្រសើរឡើងគុណភាពជីវិតរបស់ជនពិការ និងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងអនុសញ្ញាអង្គការសសហប្រជាជាតិស្តីពីសិទ្ធិជនពិការ | កម្មវិធី ACCESS បន្តធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ជនពិការ ដោយផ្តោតការយកចិត្តទុកដាក់លើ លើការបង្កើនថវិការបស់រាជរដ្ឋាភិបាល លើការអនុវត្តផែនការយុទ្ធជាតិស្តីពីជនពិការ និងការធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាសម្រាប់ជនពិការ រួមទាំងការទទួលបាននូវទីផ្សារការងារផងដែរ។ |
| លទ្ធផលសំខាន់/ លទ្ធផលពេលចប់កម្មវិធី | សមាសធាតុទី១៖ បង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីជនពិការតាមរយៈអភិក្រមផ្អែកលើសិទ្ធិមនុស្ស<br>សមាសធាតុទី២៖ បង្កើនសមត្ថភាពអង្គការជនពិការកម្ពុជាដើម្បីលើកកម្ពស់ការយល់ដឹងអំពី សេចក្តីត្រូវការរបស់ជនពិការ<br>សមាសធាតុទី៣៖ បង្កើនការទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា និងបង្កើនសមត្ថភាពមូលនីធិជនពិការក្នុងការគ្រប់គ្រងស្តារលទ្ធភាពពលកម្មកាយសម្បទា<br>សមាសធាតុទី៤៖ បង្កើនសមត្ថភាព និងបង្កើនកិច្ចសហការអ្នកសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងសហគមន៍ដើម្បីសម្រេចបាននូវការអនុវត្តសិទ្ធិរបស់ជនពិការ | កម្មវិធី ACCESS បន្តការគាំទ្រផ្តល់សេវា និងការស្តារលទ្ធភាពពលកម្មកាយសម្បទា សម្រាប់ជនពិការ។ ទិដ្ឋភាពថ្មី គឺការផ្តោតការយកចិត្តទុកដាក់លើ ចំណុចស្នូលការងារ និងមុខរបរ ដើម្បីបង្កើនបរិយាប័ណ្ណសេដ្ឋកិច្ចរបស់ជនពិការ។ |

| | **កម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា (DRIC)** | **កម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលីដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព (ACCESS)** |
|---|---|---|
| លទ្ធផលគាំទ្រ/<br>លទ្ធផលភ្លាមៗ | សមាសធាតុទី១៖ បង្កើនសមត្ថភាពក្រុមប្រឹក្សាសកម្មភាពជនពិការ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព នឹងត្រូវបានអនុវត្ត។<br>សមាសធាតុទី២៖ បង្កើនសមត្ថភាពអង្គការជនពិការកម្ពុជា និងបរិយាប័ណ្ណជនពិការ<br>សមាសធាតុទ៣៖ បង្កើនសមត្ថភាពមូលនីធិជនពិការ និងបង្កើនការទូលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា<br>សមាសធាតុទី៤៖ ឱ្យជនពិការទទួលបានសេវាស្តារតាមមូលដ្ឋានកាន់តែច្រើន និងបង្កើនសមត្ថភាពថ្នាក់ក្រោមជាតិ | កម្មវិធី ACCESS បន្តគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ មូលនីធិជនពិការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការបង្កើនថវិការបស់គាត់ ក៏ដូចជាការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។<br>កម្មវិធី ACCESS បន្តគាំទ្រមូលនីធិជនពិការក្នុងការអភិវឌ្ឍសមត្ថភាពដើម្បីគ្រប់គ្រងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា។<br>កម្មវិធី ACCESS អភិវឌ្ឍសេវារកការងារ និងមុខរបរសម្រាប់ជនពិការ។ |

## ចំណុចខុសគ្នាសំខាន់ៗរវាងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលីដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព

| | កម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី (EVAW) | កម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលីដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព (ACCESS) |
|---|---|---|
| គំរូ | ថវិការជំនួយ និងកិច្ចសន្យា គ្រប់គ្រងដោយ ដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ដោយមានការគាំទ្រពីការិយាល័យរបស់កម្មវិធីនៅក្នុងក្រសួងកិច្ចការនារី | ការអនុវត្តទាំងអស់នឹងគ្រប់គ្រងដោយ ក្រុមអ្នកម៉ៅការគ្រប់គ្រងកម្មវិធី (ថវិកាជំនួយ ការជេញថ្លៃ និងជំនួយបច្ចេកទេស) |
| ដៃគូអនុវត្ត | មានអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន ១៥៖<br>– ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ ដែលបានចុះកិច្ចសន្យាបន្តជាមួយអង្គកាចិត្តសង្គមអន្តរវប្បធម៌ អង្គការជំនួយផ្លូវច្បាប់កម្ពុជា អង្គការបន្ទាយស្រី និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ។<br>– អង្គការមូលនិធិអាស៊ី ដែលបានកិច្ចព្រមព្រៀងបន្តជាមួយអង្គការពន្លឺកុមារកម្ពុជា មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព អង្គការចិត្តសង្គមអន្តរវប្បធម៌ និងវិទ្យាស្ថានបើកទូលាយ។<br>– ទីភ្នាក់ងារអង្គការសហប្រជាជាតិសម្រាប់ស្ត្រី អង្គការយែរ មូលនិធិសម្រាប់ប្រជាជនអង្គការសហប្រជាជាតិ អង្គការចិត្តសង្គមអន្តរវប្បធម៌<br>– ទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ដែលបានចុះកិច្ចព្រមព្រៀងបន្តជាមួយអង្គការជំនួយផ្លូវច្បាប់កម្ពុជា, និងអង្គការសេវាសង្គមកម្ពុជា។<br>– អង្គការជំនួយផ្លូវច្បាប់កម្ពុជា និងអង្គការហោហ្គារ | នឹងកំណត់បានតាមរយៈដំណើរការប្រកួតប្រជែងទទួលបានថវិកាជំនួយ និងការជេញថ្លៃ។ អាចមានការចុះកិច្ចសន្យាជំនួយបច្ចេកទេសតាមរយៈទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីគាំទ្រក្រសួងកិច្ចការនារី និងការអនុវត្តគោការណ៍ណែនាំដែលមានស្រាប់។ |
| គោលដៅ | ការកាត់បន្ថយអំពើហិង្សាលើស្ត្រីនៅកម្ពុជាប្រកបដោយនិរន្តរភាព។ | ខណៈដែលយុទ្ធសាស្ត្រកម្មវិធីផ្តោតការយកចិត្តទុកដាក់ លើការផ្លាស់ប្តូរបរិបទសង្គមដែលគាំទ្រ និងជំរុញឱ្យមានអសមភាពយេនឌ័រ ហើយដែលចូលរួមចំណែកឱ្យមានអំពើហិង្សាកម្រិតខ្ពស់ ការផ្តោតអារម្មណ៍ក៏ដូចជាគណនេយ្យភាពកម្មវិធីរបស់យើងគឺការបង្កើននិរន្តរភាពនៃសេវាប្រកបដោយគុណភាព និងបរិយាប័ណ្ណ។ |
| គោលបំណង | ដើម្បីចូលរួមចំណែកឱ្យមានប្រសិទ្ធភាព ជាប្រព័ន្ធ និងគណនេយ្យភាព និងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅកម្ពុជា | កម្មវិធី ACCESS បន្តផ្តោតការយកចិត្តទុកដាក់ លើការឆ្លើយតបជាទូទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាមួយនិងការផ្តោតការយកចិត្តទុកដាក់បន្ថែមលើការបង្កើនថវិកាជាតិ សម្រាប់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងតាមរយៈយន្តការនេះក៏ដូចជាតាមរយៈថវិកាជំនួយទៅកាន់អង្គការមិនមែនរដ្ឋាភិបាលដែលមានភាពសកម្មនៅថ្នាក់ស្រុក និងថ្នាក់ឃុំ យើងនឹងអាចចូលរួមចំណែកទៅក្នុងបង្ការទប់ស្កាត់។ |
| លទ្ធផលសំខាន់/ លទ្ធផលពេលចប់កម្មវិធី | សេវា៖ ផ្តល់នូវការទទួលបានសេវាសក្តិសម និងប្រកបដោយគុណភាពជូនជនរងគ្រោះពីអំពើហិង្សានៅពេលជនរងគ្រោះស្វែងរកជំនួយ រួមទាំងការផ្តល់ជម្រើសបន្ថែមសម្រាប់សេវាបញ្ជូន។<br>ការបង្ការទប់ស្កាត់៖ បង្កើតយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ការផ្លាស់ប្តូរវិជ្ជាមានក្នុងការយល់ឃើញ, ឥរិយាបថ, អាកប្បកិរិយា, ជំនឿ, ការអនុវត្ត, និងបទដ្ឋានសង្គម។<br>យុត្តិធម៌៖ ដំណើរការស៊ើបអង្កេតមានការការពារ និងស្របច្បាប់ដែលមានភាពឆ្លើយតប ប្រសិទ្ធភាព និងប្រព្រឹត្តលើជនរងគ្រោះពីអំពើហិង្សាប្រកបដោយភាពថ្លៃថ្នូរ និងឱ្យជនប្រព្រឹត្តទទួលខុសត្រូវ។ | កម្មវិធី ACCESS នឹងរក្សាការផ្តោតការយកចិត្តទុកដាក់លើសេវា និងការពង្រឹងបណ្តាញបញ្ជូន។ យុទ្ធសាស្ត្របង្ការទប់ស្កាត់បឋមជាសាកលមិនមែនជាចំនុចផ្តោត របស់កម្មវិធី ACCESS ឡើយ ក៏ប៉ុន្តែមានការរំពឹងថាថវិកាជំនួយដល់អង្គការមិនមែនរដ្ឋាភិបាលនឹងចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងបង្ការទប់ស្កាត់ (ដូចជាការបន្តកិច្ចផ្តួចផ្តើមនានាដែលមានគោលបំណងកាត់បន្ថយឥទ្ធិពលគ្រឿងស្រវឹងដែលនាំឱ្យមានអំពើហិង្សាជាដើម)។ អភិក្រមនេះទទួលស្គាល់សក្តានុពលតួនាទីសំខាន់របស់អ្នកផ្តល់សេវា និងថ្នាក់ដឹកនាំមូលដ្ឋានក្នុងការផ្លាស់ប្តូរបរិបទសង្គមជុំវិញអំពើហិង្សា។ |

| | កម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី (EVAW) | កម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា អូស្ត្រាលីដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព (ACCESS) |
|---|---|---|
| លទ្ធផលគាំទ្រ/លទ្ធផលភ្លាមៗ | កិច្ចគាំទ្រ និងសម្របសម្រួលស្ថាប័ន៖ រដ្ឋាភិបាល, ម្ចាស់ជំនួយ, វិស័យឯកជន, និងអង្គការមិនមែនរដ្ឋាភិបាលធ្វើការរួមគ្នាដើម្បីធ្វើឱ្យប្រសើរនូវកិច្ចគាំទ្រ និងការសម្របសម្រួលស្ថាប័នស្តីពីអំពើហិង្សាលើស្ត្រី។ | កម្មវិធី ACCESS នឹងបន្តរក្សាចំណុចផ្តោតនេះ ប៉ុន្តែនឹងសង្កត់ធ្ងន់បន្ថែមលើសេដ្ឋកិច្ចនយោបាយ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ |
| | ការសិក្សាស្រាវជ្រាវ និងភស្តុតាង៖ ការសិក្សាស្រាវជ្រាវ និងភស្តុតាងអំពីអំពើហិង្សាលើស្ត្រីត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យប្រសើរនូវការរៀបចំផែនការ និងការអនុវត្តការឆ្លើយតបបញ្ចប់អំពើហិង្សាលើស្ត្រី។ | ការផ្តោតការយកចិត្តទុកដាក់ទៅលើការអនុវត្ត ដោយផ្អែកលើមូលដ្ឋានលទ្ធផលស្រាវជ្រាវពីកម្មវិធីមុនៗ។ ក្របខ័ណ្ឌត្រួតពិនិត្យតាមដាន និងវាយតម្លៃសង្កត់ធ្ងន់លើការចូលរួមចំណែកទៅនឹងកិច្ចខិតខំប្រឹងប្រែងទូលំទូលាយជាងមុនដើម្បីតាមដានការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងចូលរួមចំណែកទៅនឹងមូលដ្ឋានភស្តុតាងពាក់ព័ន្ធនឹងអភិក្រមសន្យា។ |